# ទំនៀមបញ្ចុះវត្ថុនៅក្នុងគ្រឹះប្រាសាទ

*ស្រុកខ្មែរ បានទទួលឥទ្ធិពលពីស្រុកឥណ្ឌាតាំងពីដើមគ្រឹស្តសករាជមកម្ល៉េះ។ ឥទ្ធិពលទាំងនោះរួមមាន ជំនឿ ប្រពៃណី ទំនៀមទម្លាប់ សិល្បៈ សំណង់ស្ថាបត្យកម្ម និងសាសនាពីរដែលបានជ្រួតជ្រាបចូលក្នុងសង្គមខ្មែរសម័យបុរាណ គឺព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ដែលនាំឱ្យមានការបង្កើតនូវសំណង់ស្ថាបត្យកម្មប្រាសាទជាច្រើនសម្រាប់ឧទ្ទិសដល់សាសនាទាំងពីរ។ គ្រប់សំណង់ស្ថាបត្យកម្មប្រាសាទខ្មែរនាសម័យបុរាណ តែងតែមានការបញ្ចុះថ្មនៅក្រោមគ្រឹះប្រាសាទ ដើម្បីឱ្យសំណង់មានភាពបរិសុទ្ធ គង់វង្ស រឹងមាំ ដោយការបញ្ចុះនេះ គឺធ្វើទៅតាមក្បួនច្បាប់ និងជំនឿរបស់ខ្មែរបុរាណ។ ចំពោះការបញ្ចុះនេះ មិនត្រឹមតែបញ្ចុះនៅក្រោមគ្រឹះនៃសំណង់ប្រាសាទនោះទេ ពោលគឺមានការបញ្ចុះនៅផ្នែកខាងលើនៃកំពូលប្រាសាទ នៅក្រោមជើងទម្រលិង្គ ឬរូបបដិមា បាតស្រះទឹក និងផ្នែកផ្សេងៗនៃសំណង់ស្ថាបត្យកម្មជាដើម។ ចំពោះគ្រឿងសម្រាប់បញ្ចុះនៅក្នុងគ្រឹះនៃសំណង់ប្រាសាទ ច្រើនមានដូចជា ថ្មបញ្ចុះ អណ្តើក សន្ទឹកមាស ឬវត្ថុមានតម្លៃផ្សេងទៀត។ កស្តុតាងនៃគ្រឿងសម្រាប់បញ្ចុះទាំងនេះសោត គេអាចដឹងតាមរយៈទិន្នន័យបុរាណវិទ្យា ជាពិសេសគឺការធ្វើកំណាយតែម្តង។*

*ជាក់ស្តែង ការធ្វើកំណាយបុរាណវិទ្យានៅប្រាសាទគោកតាស៊ាន ក្នុងឆ្នាំ១៩៩៧ ដែលធ្វើឡើងដោយសាលាបារាំងចុងបូព៌ា សហការជាមួយអាជ្ញាធរជាតិអប្សរា គេបានប្រទះឃើញសន្ទឹកមាសចំនួន ៦ សន្ទឹក ដែលមានចារជារូបសត្វនាគ សត្វដំរី និងជាពិសេសគឺសត្វអណ្តើក ដែលគេបានកប់នៅក្រោមគ្រឹះប្រាសាទ (រូបលេខ១)។[១] យើងពុំដឹងជាក់លាក់អំពីអត្ថន័យ និងផ្នត់គំនិតនៃការបញ្ចុះសន្ទឹកមាសនៅក្នុងគ្រឹះប្រាសាទនេះ ពោល គឺគ្រាន់តែដឹងថាកិច្ចនេះទំនងជាជំនឿ ឬទំនៀមដែលគេធ្វើឡើងដើម្បីឱ្យប្រាសាទក្លាយជាកន្លែងស័ក្តិសិទ្ធិ បរិសុទ្ធ ដែលលក្ខណៈនេះប្រហែលជាដូចទៅនឹងការបញ្ចុះសីមានៅតាមព្រះវិហារវត្តអារាមព្រះពុទ្ធសាសនាថេរវាទសព្វថ្ងៃនេះដែរ។[២]*

*ឧទាហរណ៍មួយទៀត តាមរយៈការធ្វើកំណាយនៅព្រះលានជល់ដំរី ដោយសាលាបារាំងចុងបូព៌ា នៅឆ្នាំ១៩៩៦-១៩៩៧ គេប្រទះឃើញអណ្តើកធ្វើអំពីសំណចំនួន ៦ ហើយក្នុងនោះ*

[១] Pottier 2001: 129.

[២] *ឯក កល្យា ២០០៣: ១៤*

*អត្ថបទដោយ៖ ងួន ចាន់ដារីយ៉ា*

មានអណ្ដើកប្រភេទតូចចំនួន ២ ប្រភេទធំចំនួន ៤[៣] បញ្ចុះនៅក្នុងគ្រឹះនៃសំណង់ (រូបលេខ២)។ គេឃើញរូបអណ្ដើកទាំងនេះតម្រៀបជាជួរត្រង់ពីខាងជើងទៅខាងត្បូង កែងនឹងអ័ក្សរបស់សំណង់។

មួយវិញទៀតការសិក្សាស្រាវជ្រាវ ជួសជុល និងអភិរក្សប្រាសាទកណ្ដាលស្រះស្រង់ កាលពីខែមីនារហូតដល់ខែមិថុនា ឆ្នាំ២០២០ ដោយនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ នៃអាជ្ញាធរជាតិអប្សរា គេបានធ្វើកំណាយនៅបរិវេណខាងកើតទួលប្រាសាទ ហើយបានប្រទះឃើញរូបអណ្ដើកធ្វើអំពីថ្មភក់ចំនួន ២ បែរមុខទៅជ្រុងឦសាន (រូបលេខ៣)។[៤] នៅលើស្នូកអណ្ដើក មានគម្របរាងបួនជ្រុងស្មើដែលគេអាចបិទបើកបាន ហើយនៅក្នុងស្នូកអណ្ដើកទំនងជាមានការដាក់វត្ថុមានតម្លៃនៅខាងក្នុងនោះ រួចទើបដាក់បញ្ចុះនៅក្នុងគ្រឹះរបស់សំណង់។ ចំពោះការបញ្ចុះអណ្ដើកនៅក្នុងគ្រឹះប្រាសាទនេះ ទំនងគេយល់ថា អណ្ដើក គឺជាអវតាររបស់ព្រះវិស្ណុ ដែលបានទ្រភ្នំមន្ទរកុំឱ្យលេចចូលទៅក្នុងសមុទ្រ នៅក្នុងពេលកូរសមុទ្រទឹកដោះដើម្បីទទួលបានទឹកអម្រឹត។[៥] ហេតុដូច្នេះហើយយើងអាចពិចារណាបានថាគំនិតខ្មែរនៅពេលនោះ ទំនងមានជំនឿទៅលើការបញ្ចុះរូបអណ្ដើកនៅក្នុងបាតប្រាសាទ ដោយគេគិតថាអណ្ដើកអាចទ្រសំណង់ដែលជាទីសក្ការឱ្យស្ថិតស្ថេរគង់វង្ស និងរឹងមាំ។[៦]

លក្ខណៈគួរកត់សម្គាល់មួយទៀតនោះ គឺនៅក្នុងឆ្នាំ១៩៦៨ គេធ្លាប់ប្រទះឃើញការបញ្ចុះថ្មនៅក្រោមគ្រឹះប្រាសាទព្រះគោ ដែលថ្មនេះមានរន្ធតូចៗរាងដូចចតុកោណកែងចំនួន ១៦ នៅព័ទ្ធជុំវិញរន្ធកណ្ដាលធំមួយ (រូបលេខ៤)។ នៅក្នុងរន្ធតូចៗទាំងនោះ ប្រហែលជាអាចដាក់គ្រាប់ធញ្ញជាតិ ដូចជាស្រូវ សណ្ដែក ល្ង លោហៈ ជាដើម រីឯរន្ធធំនៅចំកណ្ដាលគេអាចដាក់វត្ថុមានតម្លៃផ្សេងៗទៀតដូចជាត្បូង លោហៈធាតុដែលមានតម្លៃ ។ល។ ការដាក់គ្រាប់ធញ្ញជាតិ ស្រូវ ល្ង និងវត្ថុផ្សេងទៀតនៅក្នុងថ្មរួចដាក់បញ្ចុះនៅក្នុងគ្រឹះរបស់សំណង់ប្រាសាទ ទំនងជាគំនិត ឬជំនឿដែលតំណាងភោគផល ការលូតលាស់ និងរីកចម្រើន។

ជារួមមក ការបញ្ចុះថ្ម អណ្ដើក សន្ទឹកមាស និងវត្ថុមានតម្លៃផ្សេងទៀតនៅក្រោមគ្រឹះរបស់សំណង់ស្ថាបត្យកម្ម ទំនងមានអត្ថន័យរួមមួយ ពោល គឺដើម្បីឱ្យបូជនីយដ្ឋាននោះមានភាពបរិសុទ្ធ គង់វង្ស រឹងមាំ និងមានភាពរីកចម្រើន។ ទំនៀមនៃការបញ្ចុះនេះទៀតសោត ក៏នៅតែមានបន្តរហូតមកដល់សម័យបច្ចុប្បន្ន ជាក់ស្ដែង មុននឹងសាងសង់ព្រះវិហារវត្តអារាមណាមួយ គេត្រូវ

---

[៣] Pottier 1997: 384.

[៤] ជា សុជាតិ ឈូក សុម៉ាឡា សាន កុសល ២០២០: ១២-១៤។

[៥] Roveda 2005: 188; Thomas 1999: 93.

[៦] ឯក កល្យា ២០០៣: ១៤។

អត្ថបទដោយ៖ ងួន ចាន់ដារីយ៉ា

ធ្វើកិច្ចពិធីប្រុងពាលី និងបញ្ចុះបឋមសិលា (ថ្មដំបូង) នៅក្រោមគ្រឹះជាមុនសិន ហើយបន្ទាប់ពីសាងសង់រួចទើបគេធ្វើពិធីបញ្ចុះសីមានៅតាមទិសទាំង៨ និងសីមាកិល នៅចំកណ្ដាលព្រះវិហារ។ ដោយឡែក ការសាងសង់លំនៅដ្ឋានក៏មិនសូវខុសគ្នាប៉ុន្មានដែរ ពោលគឺជួនកាលគេមានបញ្ចុះមាសស្រួយ ឬមាសសន្លឹក ឬគ្រឿងអលង្ការនៅក្រោមបាតសសរកន្ទោង ក្នុងជំនឿថាលំនៅដ្ឋាននោះនឹងពោរពេញដោយសេចក្ដីសុខ រីកចម្រើន គង់វង្ស រឹងមាំ។



រូបលេខ១៖ សន្លឹកមាសដែលមានចាររូបសត្វនាគ ដំរី អណ្ដើកនៅប្រាសាទគោកតាស៊ាន

( ប្រភពរូប៖ CHRISTOPE POTTIER)

អត្ថបទដោយ៖ ផ្លូន ចាន់ដារីយ៉ា



Grande tortue en plomb (l=65cm)

*រូបលេខ២២៖ អណ្ដើកសំណរនៅព្រះលានជល់ដំរី*
(ប្រភពរូប ៖ EFEO)



*រូបលេខ២៣៖ រូបអណ្ដើកធំនិងតូចមើលពីជ្រុងឦសាន*

*( ប្រភពរូប ៖ ជា សុជាតិ, អាជ្ញាធរជាតិអប្សរា )*

អត្ថបទដោយ៖ ងួន ចាន់ដារីយ៉ា



រូបលេខ៤៖ ថ្មបញ្ចុះនៅប្រាសាទព្រះគោ

( ប្រភពរូប ៖ EFEO)

## ឯកសារយោង


**ឯក កល្យា**

២០០៣, "ជំនឿអណ្ដើកក្នុងសង្គមខ្មែរ" ភ្នំពេញ

**ជា សុជាតិ, ឈូក សុម៉ាឡា, សាន កុសល**

២០២០, "របាយការណ៍បឋមស្ដីពីកំណាយស្រាវជ្រាវរចនាសម្ព័ន្ធសំណង់នៅលើកោះកណ្ដាលស្រះស្រង់" នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ, អាជ្ញាធរជាតិអប្សរា។

**Pottier, Christophe**

1997, La restauration du perron nord de la terrasse des Éléphants à Angkor Thom. Rapport sur la première année de travaux (avril 1996-avril 1997), *BEFEO*, Tome 84, pp.371-401, Paris

2001, “Perspective de la mission archaeologique France-Khmer sur láménagement du territory Angkor”, *UDAYA*, Numéro 2, Phnom Penh

**Roveda, Victorio**

2005, “*Image of the gods*”, Bangkok

**Thomas, Paul**

1999, *“Epics, Myths and Legends of India*”, Treasure House of Books, Boomba


អត្ថបទដោយ៖ ង៉ួន ចាន់ដារីយ៉ា